ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

*ថ្ងៃ អង្គារ ២ រោច ខែ មាឃ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០២៣*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកា ប្រចាំឆ្នាំ ២០២២
# របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បានដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួង ដើម្បីពិភាក្សាលើ ***"របាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ ២០២២"*** របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួង និងថ្នាក់ដឹកនាំអង្គភាពនានា ក្រោមឱវាទ និងក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ។

កិច្ចប្រជុំបានរៀបចំឡើងដើម្បីពិភាក្សាលើលទ្ធផលនៃការតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកាដែលអង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលរបស់ក្រសួងសម្រេចបានក្នុងឆ្នាំ ២០២២ ដោយពិនិត្យលើទិដ្ឋភាពហិរញ្ញវត្ថុ, ទិដ្ឋភាពសមិទ្ធកម្ម, អនុលោមតាមលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអនុវត្តថវិកាកម្មវិធី និងថវិកាសមិទ្ធកម្ម, ព្រមទាំងកំណត់បញ្ហាប្រឈម និងវិធានការដោះស្រាយ ដើម្បីជំរុញការអនុវត្តការងារនៅឆ្នាំបន្តបន្ទាប់ឱ្យសម្រេចបានតាមគោលដៅដែលបានដាក់ចេញ ដូចដែលក្រសួងបានរៀបចំជារៀងរាល់ឆ្នាំ ចាប់ពីការិយបរិច្ឆេទថវិកាឆ្នាំ ២០១៥ មក ។ ជាមួយគ្នានេះ, កិច្ចប្រជុំ ក៏ពិនិត្យផងដែរនូវបទពិសោធន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការអនុវត្តនីតិវិធីចំណាយតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System - FMIS) ទាំងស្រុង ក្នុងខណៈដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាក្រសួងមួយ ក្នុងចំណោមក្រសួងចំនួនពីរ ដែលត្រូវបានដាក់ឱ្យអនុវត្តនីតិវិធីចំណាយតាមប្រព័ន្ធ FMIS ទាំងស្រុង កាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០២២ កន្លងទៅ ។

សម្រាប់ទិដ្ឋភាពហិរញ្ញវត្ថុ, ឆ្នាំ ២០២២ នេះ, ក្នុងអំឡុងពេលដែលប្រទេសកម្ពុជានៅបន្តរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងស្ថានភាពនយោបាយ និងសេដ្ឋកិច្ចសកល ការប្រមូលចំណូលរបស់ក្រសួងជារួម (ដោយមិនបូកចំណូលពន្ធដារថ្នាក់ក្រោមជាតិ) សម្រេចបានលទ្ធផលល្អគួរកត់សម្គាល់ ក្នុងទំហំ 28,8 ទ្រីលានរៀល ស្មើនឹង 99,1% ធៀបច្បាប់ (លទ្ធផលប្រចាំឆ្នាំ២០២១ សម្រេចបាន 98,5% ធៀបច្បាប់) ក្នុងនោះ ថ្នាក់កណ្តាល សម្រេចបាន 28,77 ទ្រីលានរៀល ស្មើនឹង 99,1% ធៀបច្បាប់ រីឯថ្នាក់មូលដ្ឋាន សម្រេចបាន 633,5 លានរៀល ស្មើនឹង 157,6% ធៀបច្បាប់ ។ ចំណូលសារពើពន្ធ ដែលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ សម្រេចបានលើសផែនការ ក្នុងរង្វង់ 111,5% ធៀបច្បាប់ (គយនិងរដ្ឋាករ 104,9%, ពន្ធដារថ្នាក់ជាតិ 117,5% និងពន្ធដារថ្នាក់

ក្រោមជាតិ 124,6%) ។ ដោយឡែក ចំណូលប្រមូលបានសរុបរបស់ក្រសួងទាបជាងផែនការបន្តិច ដោយសារ ចំណូលមិនមែនសារពើពន្ធ និងចំណូលមូលធន ប្រមូលបានទាបជាងច្បាប់កំណត់ ត្រឹម 82,2% និង 71,3% ធៀបច្បាប់រៀងគ្នា ។

សម្រាប់ការអនុវត្តចំណាយប្រចាំឆ្នាំ ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានប្រមាណ 96,0% នៃឥណទានថ្មី (តួលេខធានាចំណាយ) និងប្រមាណ 89,7% នៃឥណទានថ្មី (តួលេខអាណត្តិទូទាត់) ។

សម្រាប់សមិទ្ធកម្មប្រចាំឆ្នាំ ២០២២, ជារួម សម្រេចបានពិន្ទុប្រមាណ 94/100 ធៀបនឹងគោលដៅសូចនាករកម្រិតអនុកម្មវិធីដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ក្នុងនោះ គោលបំណងគោលនយោបាយទី ១ សម្រេចបានក្នុងរង្វង់ 93/100 និងគោលបំណងគោលនយោបាយទី ២ សម្រេចបានក្នុងរង្វង់ 95/100 រីឯសមិទ្ធកម្មគ្រប់អង្គភាពថវិកា សម្រេចបានប្រសើរ ចាប់ពី 85/100 ឡើងទៅ) ។ បើពិនិត្យមើលស្ថានភាពគោលដៅសូចនាករ កម្រិតអនុកម្មវិធីឃើញថាក្នុងចំណោម គោលដៅសូចនាករសរុបចំនួន 211, សម្រេចស្ថាពរ បានចំនួន 171 និងសម្រេចមិនបានពេញលេញ ប៉ុន្តែមានវឌ្ឍនភាពបង្គួរ ចំនួន 40 ។

ជារួម, ការត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ ២០២២ បានបង្ហាញថាអង្គភាពថវិកាក្រោមឱវាទ និងក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងធ្វើការផ្លាស់ប្តូរដើម្បីឆ្ពោះទៅការទទួលខុសត្រូវចំពោះសមិទ្ធកម្ម ។ ការចាប់ផ្តើមអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះជាវិញ្ញាសាថ្មីសម្រាប់គ្រប់អង្គភាព ។ ដោយឡែក, នីតិវិធីចំណាយថ្មី នៅតែជាកម្មវត្ថុនៃការកែលម្អដើម្បីភាពទាន់ពេល និងគណនេយ្យភាព ។ ទន្ទឹមនេះ, ការដាក់ឱ្យអនុវត្តនីតិវិធីចំណាយតាមប្រព័ន្ធ FMIS ទាំងស្រុង ជាចំណុចរបត់ថ្មី នៃការអនុវត្តថវិកានៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលអគ្គនាយកដ្ឋានជំនាញ និងក្រុមការងារគ្រប់គ្រងគម្រោង FMIS អាចដកពិសោធន៍ សម្រាប់ការពង្រីកវិសាលភាពទៅក្រសួង ស្ថាប័នដទៃ ។

លទ្ធផលនៃការត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ ២០២២នេះ បានបង្ហាញអំពីការបន្តកសាងភាពជាគំរូ ក្នុងការអនុវត្តថវិកាកម្មវិធី ស្របតាមទិសដៅកំណត់ដោយ**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដែលបង្ហាញពីការត្រៀមលក្ខណៈបានសមស្រប សម្រាប់ការអនុវត្តថវិកាសមិទ្ធកម្មនៅឆ្នាំ ២០២៣ ។